**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ៥៤២.ថទ.៣៤១-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

លោកប្រធានតុលាការគ្រប់ជាន់ថ្នាក់

សូមជ្រាប។

**កម្មវត្ថុ:** ការបន្តនិរន្តរភាព នៃការបញ្ជូនសេចក្តីចម្លងសាលក្រមឬសាលដីកាព្រហ្មទណ្ឌស្ថាពរមកក្រសួងយុត្តិធម៌ ដើម្បីរៀបចំបញ្ជីថ្កោលទោស ។

តាមកម្មវត្ថុខាងលើ សូមលោកប្រធានចាត់ការបញ្ជូនជាបន្តនូវសេចក្តីចម្លងសាលក្រមឬសាលដីកាព្រហ្មទណ្ឌស្ថាពរ មកក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់ ដោយអនុលោមតាមខ្លឹមសារនៃលិខិតលេខ ២៩៨-ថទ.៣៨១-៩៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ដែលក្រសួងយុត្តិធម៌បានផ្ញើជូនតុលាការគ្រប់ជាន់ថ្នាក់រួចហើយដូចមានជូនភ្ជាប់មកជាមួយនេះស្រាប់ ។

សូមជំរាបថា តុលាការ មិនត្រូវខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសាវតាជាតិរបស់ទណ្ឌិត ក្នុងសាលក្រមឬសាលដីការបស់តុលាការ ដោយសារមូលហេតុ ជនល្មើសគេចខ្លួនបាត់នោះទេ ពីព្រោះជនល្មើសគេចខ្លួនបាត់មានពីរប្រភេទ៖

-ប្រភេទទី១ គឺ ជនល្មើសគេចខ្លួនបាត់ ប៉ុន្តែមានសាវតាជាតិគ្រប់គ្រាន់ជនល្មើសគេចខ្លួនបាត់ ប្រភេទទី១នេះទើបតុលាការមានសិទ្ធិដាក់ជំនុំជម្រះសម្រេចសេចក្តីកំបាំងមុខតាមច្បាប់បាន ។

-ប្រភេទទី២ គឺជនល្មើស ដែលគេចខ្លួនបាត់គ្មានសាវតាជាតិ ។ ជនល្មើសប្រភេទនេះព្រះរាជអាជ្ញាត្រូវសម្រេចបង្អង់បណ្តឹងអាជ្ញា ហើយមិនអាចសម្រេចចោទប្រកាន់ជូនទៅតុលាការជំនុំជម្រះសម្រេចសេចក្តីកំបាំងមុខបានទេ លើកលែងតែអញ្ញាតជនដែលបានប្រព្រឹត្តបទល្មើសជលផលរុក្ខាប្រមាញ់ គយនិងពន្ធដារ ។

ចំពោះសំណុំឯកសារទាក់ទងនឹងរឿងព្រហ្មទណ្ឌ ដែលគ្មានកំណត់អំពីសាវតាជាតិរបស់ជនល្មើសអយ្យការនឹងតុលាការត្រូវណែនាំឱ្យនគរបាលយុត្តិធម៌ស្រាវជ្រាវនិងកំណត់អំពីសាវតាជាតិនេះឱ្យបានច្បាស់លាស់ ។

ក្រសួងមានសុទិដ្ឋិនិយមនឹងសង្ឃឹមថា លោកប្រធានតុលាការគ្រប់ជាន់ថ្នាក់នឹងយកចិត្តទុកដាក់ធ្វើការងារនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ជូនក្រសួង ដើម្បីរួមចំណែកទទួលខុសត្រូវក្នុងការចេញលិខិតថ្កោលទោសជូនប្រជាពលរដ្ឋនឹងអង្គការរដ្ឋផ្សេងៗ យកទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វីធុន**